**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៥៩ សហវ-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ "គ.អ.ប.ជ" ដើម្បីបំពេញមុខងារជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ លើបេសកកម្មរៀបចំនិងអភិវឌ្ឍមុខងារបច្ចេកទេស និងអនុវត្តគម្រោងបញ្ជរតែមួយជាតិ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. លោក **នួន ច័ន្ទរិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២. លោក **ផាន អូន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកាំកុងត្រូល | អនុប្រធាន |
| ៣. លោក **ផា អេងទ៉េង** | ប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. លោកជំទាវ **ជា សិរី** | អគ្គនាយកបច្ចេកទេស នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥. លោក **នាង ម៉ៅ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦. លោក **ហូ ស៊ីវឃ៊ីង** | ប្រធាននាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. លោក **ជា ចាំរក្សា** | ប្រធានការិយាល័យបញ្ញត្តិកម្មនៃនាយកដ្ឋានបញ្ញត្តិកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨. លោក **ហេង ម៉ិនគៀត** | ប្រធាននាយកដ្ឋានឱសថ បរិក្ខារពេទ្យ ចំណីអាហារ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល | សមាជិក |
| ៩. លោក **ឃុន ហេង** | ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១០. លោក **នូច បូរី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១. លោក **សួន សុធឿន** | អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. លោក **ថោង ទីរ៉ូ** | នាយក នៃនាយកដ្ឋាននាវាចរ-កណ្តូធារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៣. លោក **ជាម សុផាន្នេរ** | ប្រធានអង្គភាពបច្ចេកវិទ្យា/ព័ត៌មានវិទ្យា នៃកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៤. លោក **ជួន ច័ន្ទសោភា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥. លោក **សុខ រតនា** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៦. លោក **ម៉ូ សុធារិទ្ធ** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៧. លោក **ណយ សុផាន់ណារិទ្ធ** | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

4/

| | | |
|---|---|---|
| ១៨. លោក សាន ចំរើន | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៩. លោក ផាន់ តារិទ្ធ | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២០. លោក មឿន សុភក្ដី | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២១. លោក ទិាន់ ទុធថា | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២២. លោក មាស ឪសត្យា | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

**ប្រការ ២.-**

គ.អ.ប.ជ មានតួនាទី និងភារកិច្ចដូចតទៅ ÷

- កសាងផែនការសកម្មភាព រៀបចំសមាសភាគបច្ចេកទេស និងផែនការថវិកាសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- កសាងផែនការយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- កសាងឯកសារលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសអ្នកជំនាញបច្ចេកទេស ឬ ក្រុមហ៊ុន មកផ្តល់ប្រឹក្សាការងារអភិវឌ្ឍ និងអនុវត្តគម្រោង
- សម្របសម្រួល ទំនាក់ទំនង និងផ្តល់អនុសាសន៍ដល់ក្រុមការងារអភិវឌ្ឍនិងអនុវត្តគម្រោងប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ សម្រាប់ការតភ្ជាប់មកប្រព័ន្ធបញ្ជរតែមួយជាតិ
- ស្វែងរកប្រភពថវិកានិងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- ធ្វើរបាយការណ៍វឌ្ឍនភាពជូនគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងដោយប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

**ប្រការ ៣.-**

ប្រកាស ឬសេចក្តីសម្រេចណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/ លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងវិស័យឯកជន ពាក់ព័ន្ធ
- គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ